បានទទួលដំណឹង។ បានចូលរួម។ បានរាប់ចំនួន។

# ព័ត៌មាន ជំរឿនឆ្នាំ2020 របស់អ្នកត្រូវបានការពារ

សម្រាប់ជំរឿនឆ្នាំ2020 ក្រសួងជំរឿនសហរដ្ឋអាមេរិក ណែនាំឲ្យបំពេញកម្រងសំណួរតាមអនឡាញ។ មិនថាតើអ្នកបំពេញកម្រងសំណួរតាមអនឡាញ ឬបែបបទបំពេញជាក្រដាសនោះទេ ការការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកមានសារៈសំខាន់បំផុត។

តាមច្បាប់ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក មិនអាចប្រើប្រាស់ប្រឆាំងនឹងអ្នកទេ ហើយក្រសួងជំរឿនសហរដ្ឋអាមេរិកបានចាត់វិធានការសន្តិសុខដើម្បីធានាថាកិច្ចដំណើរការនេះមានសុវត្ថិភាព និងសន្តិសុខពេញលេញ។

## ការរក្សាសម្ងាត់



**មាត្រា13**

មាត្រា 13 នៃក្រមសហរដ្ឋអាមេរិក ហាមឃាត់មិនឲ្យក្រសួងជំរឿនសហរដ្ឋអាមេរិកធ្វើការផ្សព្វផ្សាយព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបាន ដែលអ្នកបានរាយការណ៍ជូនទីភ្នាក់ងារឬមន្ត្រីរដ្ឋាភិបាលណាមួយ (រួមទាំងមន្ត្រីអន្តោប្រវេសន៍ ឬទីភ្នាក់ងារអនុវត្តច្បាប់ណាមួយ) អង្គភាពខាងក្រៅ ឬតុលាការផ្លូវច្បាប់ សម្រាប់មូលហេតុណាមួយឡើយ។

**សច្ចាប្រណិធានសម្រាប់ការធ្វើជំរឿន**

រាល់បុគ្គលិកក្រសួងជំរឿនសហរដ្ឋអាមេរិក ត្រូវធ្វើសច្ចាប្រណិធានពេញមួយជីវិត ដើម្បីធ្វើការការពារអត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នក និងមិនអនុញ្ញាតឲ្យប្រើប្រាស់ព័ត៌មានដែលអ្នកផ្តល់ឲ្យ ប្រឆាំងនឹងអ្នកសម្រាប់មូលហេតុណាមួយឡើយ។ ការបំពានលើច្បាប់នេះ អាចត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររបស់សហព័ន្ធរហូតដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់ $250,000 ឬទាំងពីរករណីនេះ។

## ការការពារសន្តិសុខលើបណ្តាញអ៊ីនធឺណិត

**ច្បាប់ស្តីពីលើកកម្ពស់សុវត្ថិភាពសន្តិសុខលើបណ្តាញអ៊ីនធឺណិតរបស់សហព័ន្ធ**

(Federal Cybersecurity Enhancement Act)

ច្បាប់ស្តីពីលើកកម្ពស់សុវត្ថិភាពសន្តិសុខលើបណ្តាញអ៊ីនធឺណិតរបស់សហព័ន្ធ ឆ្នាំ 2015 ធានាថា ព័ត៌មាននិងទិន្នន័យរបស់អ្នក ទទួលបានការការពារពីហានិភ័យនៃបញ្ហាសន្តិសុខលើបណ្តាញអ៊ីនធឺណិតពីខាងក្រៅ។ ឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទរបស់អ្នក នឹងមិនត្រូវបង្ហាញ និងចុះផ្សាយឡើយ។



**បញ្ជរធ្វើជំរឿន**

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការឆ្លើយតបទៅនឹងការធ្វើជំរឿនតាមអនឡាញ សូមចូលទៅកាន់ census.lacity.org ដើម្បីស្វែងរកបញ្ជរធ្វើជំរឿនដែលនៅក្បែរអ្នក។

ទីក្រុង Los Angeles និងផ្តល់ដំណោះស្រាយ(នានា) យ៉ាងសមស្រប ដើម្បីធានាការប្រើប្រាស់ដោយស្មើភាពគ្នានូវកម្មវិធី សេវាកម្ម និងមន្ទីរវេជ្ជស្ថានរបស់ខ្លួនសម្រាប់មនុស្សដែលមានពិការភាព។ ដើម្បីធ្វើការស្នើសុំ សូមទាក់ទងទៅនាយកដ្ឋានផ្នែកពិការភាពតាមរយៈ DOD.Contact@lacity.org ឬ (213) 202-5668 ជាមុន ក្នុងរយៈពេលប្រាំថ្ងៃធ្វើការឬលើសពីនេះ។

Eric Garcetti @MayorOfLA

**census.lacity.org**

**#2020Census**